**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ**.....១៣១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគទីតាំងចំនួន០៣ កន្លែង របស់មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តកំពង់ឆ្នាំង និង ទីតាំងមន្ទីរសុខាភិបាល ខេត្តបន្ទាយមានជ័យ

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពីការប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/០៨០៦/៣៣៧ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និង បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និង នីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-លិខិតលេខ ២០៦ សណ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧ របស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

-របាយការណ៍ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៧ ស្តីពីការចុះអង្កេតដីធ្លី របស់គណៈកម្មការចំរុះ

-លិខិតលេខ ១៣៨ ស.ន.ថ.ហ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៧ របស់ក្រសួងសុខាភិបាល

-លិខិតលេខ ៥៩១ ស.ន.ថ.ហ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៧ របស់ក្រសួងសុខាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវទីតាំងដី០៣កន្លែង របស់មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តកំពង់ឆ្នាំង និង ទីតាំងមន្ទីរសុខាភិបាល ខេត្តបន្ទាយមានជ័យ ដើម្បីធ្វើការផ្លាស់ប្តូរជាមួយនូវទីតាំងថ្មី និង សំណង់ថ្មី របស់ភាគីឯកជន។

**មាត្រា ២.-**

ការកត់ត្រាទ្រព្យសម្បត្តិថ្មី របស់មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តកំពង់ឆ្នាំង និង មន្ទីរសុខាភិបាល ខេត្តបន្ទាយមានជ័យ ក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្ត ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ក្រសួងសុខាភិបាល សាលាខេត្តកំពង់ឆ្នាំង សាលាខេត្តបន្ទាយមានជ័យ និង មន្ទីរជំនាញពាក់ព័ន្ធចំណុះខេត្តកំពង់ឆ្នាំង និង ខេត្តបន្ទាយមានជ័យ ស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល។

**មាត្រា ៣.-**

ការបំពេញបែបបទធ្វើកម្មសិទ្ធិរបស់ភាគីឯកជនទៅលើទីតាំងរបស់រដ្ឋ នូវដី០៣កន្លែងរបស់មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តកំពង់ឆ្នាំង និង ទីតាំងមន្ទីរសុខាភិបាល ខេត្តបន្ទាយមានជ័យ ត្រូវប្រព្រឹត្តទៅតាមច្បាប់ និង គោលការណ៍កំណត់ជាធរមាន។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង អភិបាលគ្រប់ខេត្តពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យ សម្តេច នាយករដ្ឋមន្ត្រី
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- ដូចមាត្រា ៥
- ឯកសារ-កាលប្បវត្តិ